# ប្រវត្តិនៃការកកើតកំណាព្យខ្មែរ

ជនជាតិខ្មែរជាម្ចាស់ដែនដីសុវណ្ណភូមិនេះតាំងពីសម័យយូរលង់ណាស់មកហើយ គឺតាំងពីមុន គ.ស មកម្ល៉េះ។ ដូច្នេះកំណាព្យខ្មែរក៏មានអាយុកាលដ៏យូរលង់ជាមួយនោះផងដែរ។

**ក. អំពីឥទ្ធិពលនៃលទ្ធិ ឬសាសនាក្នុងសង្គមខ្មែរ**

*លទ្ធិព្រលឹង

*ព្រហ្មញ្ញសាសនា

*ព្រះពុទ្ធសាសនា

ព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាហូរចូលមកក្នុងកម្ពុជាតាំងពី ៣០៩ ឆ្នាំមុន គ.សមកម្ល៉េះ *(ដកស្រង់ឯកសារប្រវត្តិព្រះពុទ្ធសាសនានៅប្រទេសខ្មែរដោយព្រះភិក្ខុប៉ាង ខាត់)*។

**ខ. កំណាព្យខ្មែរ**

ផ្អែកតាមអ្នកស្រាវជ្រាវតន្ត្រីខ្មែរឃើញថាកំណាព្យខ្មែរកើតពីប្រភព ២៖

*ឃើញក្នុងទំនុកចម្រៀងភ្លេងអារក្ស

*ឃើញក្នុងទំនុកចម្រៀងបទភ្លេងប្រពៃណីសម័យរៀបអាពាហ៍ពិពាហ៍ព្រះបាទហ៊ុន ទៀន និងព្រះនាងលីវយី (ព្រះថោង និងនាងនាគ)។ ដូច្នេះយើងអាចបែបចែកការកកើតកំណាព្យខ្មែរមាន ៣ ដំណាក់កាល។

***»ដំណាក់កាលទី ១៖ សម័យមុនអង្គរ (មាន ២បទ)***

-នគរភ្នំ៖ បទពាក្យ ៤ ឬបទមេ ៤

-ចេនឡា៖ បទបត្យាវត្ត

***»ដំណាក់កាលពី ២៖ សម័យអង្គរ (មាន ៥បទ)***

-កាកគតិ

-ព្រហ្មគតិ

-ពំនោល

-ភុជង្គលីលា

-បន្ទោលកាក

នាសតវត្សទី ១៥ (ឆ្នាំ ១៤៩៨) នៅក្នុងស្នាដៃល្បើកអង្គរវត្តរបស់អ្នកប៉ាង ទើបកំណាព្យទាំង ៥ នេះមានឈ្មោះដូចសព្វថ្ងៃ (ក្នុងរឿងរាមកេរ្តិ៍ពីខ្មែរទី ១ ដល់ទី ១០)។

*»ដំណាក់កាលពី ៣៖ សម័យក្រោយអង្គរ (មាន ៧បទ)*

សម័យប្រប្រូកប្របល់ (សៀមវាយលុកក្រុងអង្គរ) ប្រហែលជាសម័យលង្វែក ឬឧត្តុង្គ។ មានបទពាក្យ ៦ ដែលរកឃើញក្នុងរឿងរាមកេរ្តិ៍ពីខ្សែ ៧៥ ដល់ ៨០ ដែលជាស្នាដៃបន្ត។

សម័យចតុមុខ យើងឃើញមានកកើតកំណាព្យជាមូលដ្ឋាន និងកំណាព្យបំបែកចេញពីច្បាប់ដើមជាច្រើនទៀត។ កំណាព្យជាមូលដ្ឋានគ្រឹះមាន ៦ បទគឺ៖

-បទពាក្យ ៧

-បទពាក្យ ៨

-បទពាក្យ ៩

-បទពាក្យ ១០

-បទពាក្យ ១១

-បទពាក្យ ១២

*»កំណាព្យមិនដឹងសម័យកាល៖*

-បទឥន្ទ្រជិត (ទើបរកឃើញឆ្នាំ ២០០១ ដោយលោក វ៉ែន សុន)

-បទទន្សាយទីសទាស (បាត់)

-បទមាន់ទឹកបណ្តើរកូន (បាត់)

*            *

*